# កម្មវិធីធ្វើសួន
# លក្ខខណ្ឌអតិថិជន

## និយមន័យ

- “LBUD” សំដៅលើនាយកដ្ឋានទឹកភ្លើងក្រុងឡុងប៊ិច។
- “ក្រុង” សំដៅលើសាលាក្រុងឡុងប៊ិច។
- “កម្មវិធី” សំដៅលើកម្មវិធីធ្វើសួនរបស់សាលាក្រុងឡុងប៊ិច។
- “ម្ចាស់ទ្រព្យ” ជាម្ចាស់អចលនទ្រព្យ (វាលស្មៅ) ដែលគ្រប់លក្ខខណ្ឌសម្រាប់ការរៀបចំសួនឡើងវិញពីកម្មវិធីនេះ។
- “តំបន់រៀបចំសួនឡើងវិញ” គឺសំដៅទៅទីធ្លាខាងមុខផ្ទះ និងចំណែកដីនៅជាប់គែមផ្លូវ ដែលត្រូវលក្ខខណ្ឌសម្រាប់ការរៀបចំសួនឡើងវិញពីកម្មវិធីនេះ។
- “LIHEAP” គឺជាកម្មវិធីជំនួយថាមពលសម្រាប់លំនៅឋានប្រាក់ចំណូលទាប។
- “LIHWAP” គឺជាកម្មវិធីជំនួយទឹកសម្រាប់គ្រួសារប្រាក់ចំណូលទាប។

## លក្ខខណ្ឌទូទៅ

- ម្ចាស់អលនទ្រព្យត្រូវដាក់ពាក្យសុំជំនួយពីកម្មវិធីនេះ និងព្រមព្រៀងតាមលក្ខខណ្ឌកំណត់របស់កម្មវិធី និងដាក់ឯកសារចាំបាច់ដើម្បីបញ្ជាក់អំពីភាពគ្រប់លក្ខខណ្ឌនៃប្រាក់ចំណូល។
- បងប្អូនអាចដាក់ពាក្យសុំជំនួយពីកម្មវិធីនេះ បានតែមួយប៉ុណ្ណោះ សម្រាប់ម្ចាស់អចលនទ្រព្យមួយ (LBUD រក្សាសិទ្ធិក្នុងការផ្ទៀងផ្ទាត់ភាពជាកម្មសិទ្ធិរបស់អចលនទ្រព)។
- អចលនទ្រព្យត្រូវតែបិតក្រោមកម្មសិទ្ធិគ្រប់គ្រងរបស់ម្ចាស់អចលនទ្រព្យនោះ ដើម្បីបំពេញលក្ខខណ្ឌសម្រាប់កម្មវិធីនេះ។
- តំបន់ដែលត្រូវរៀបចំសួនឡើងវិញទាំងនេះត្រូវតែជា៖
  - សួនខាងមុខ និងដីនៅជាប់គែមផ្លូវ។
  - តំបន់ដែលមានក្រាលស្មៅ turf (ស្មៅនោះត្រូវតែជាស្មៅរស់ នៅពេលដែលដាក់ពាក្យសុំនេះ)។
  - តំបន់ដែលមិនដែលទទួលបានថវិកាពីគម្រោងឈូសស្មៅ turf ចេញរបស់ LBUD។
  - មានគណនី LBUD ដំណើរការមួយ សម្រាប់ទទទួលទឹកដែលដឹកទៅដល់កន្លែងនោះ។
  - តំបន់រៀបចំសួនឡើងវិញ ត្រូវតែមានប្រព័ន្ធស្រោចស្រពស្រាប់។
  - លទ្ធភាពក្នុងការផ្តល់ការថែទាំ នៅពេលគម្រោងធ្វើសួននេះបានរួចរាល់ សម្រាប់រយៈពេលរហូតដល់ ៥ ឆ្នាំ។

## ការទទួលខុសត្រូវរបស់អតិថិជន

- ម្ចាស់អចលនទ្រព្យ មានការទទួលខុសត្រូវទាំងស្រុង លើគុណភាព សោភ័ណភាព និងការថែទាំតំបន់ដែលរៀបចំសួនឡើងវិញនោះ សម្រាប់រយៈពេល ៥ ឆ្នាំ ក្រោយពីថ្ងៃធ្វើរួច។ បើម្ចាស់អចលនទ្រពមានបញ្ហាក្នុងការថែទាំតំបន់សួនថ្មីនោះ ខ្លួនត្រូវជូនដំណឹងទៅ LBUD។ LBUD រក្សាសិទ្ធិតាមឆន្ទានុសិទ្ធិរបស់អ្នកគ្រប់គ្រងទូទៅ ដើម្បីស្នើសុំការទូទាត់ប្រាក់ ២៥០ ដុល្លារ ពីម្ចាស់អចលនទ្រព្យ ដើម្បីប្រើប្រាស់សម្រាប់បង់ថ្លៃថែទាំដោយសារការមិនយកចិត្តទុកដាក់មើលថែរបស់ម្ចាស់អចនលទ្រព្យ។
- ម្ចាស់អចនលទ្រព្យមានការទទួលខុសត្រូវ ចំពោះការអនុវត្តតាមច្បាប់ជាធរមាន លិខិតអនុញ្ញាត បទបញ្ញាក្រម គោលនយោបាយ កិច្ចព្រមព្រៀង និងលក្ខខណ្ឌដែលអនុវត្តចំពោះគម្រោងចូកវាលស្មៅ/កែសួន។
- អចលនទ្រព្យនៅក្នុងសង្កាត់ប្រវត្តិសាស្ត្រទាំងនោះ អាចតម្រូវឲ្យមានលិខិតអនុញ្ញាតពិសេសពីសាលាក្រុង និងការសុំលិខិតទាំងនេះ គឺជាការទទួលខុសត្រូវទាំងស្រុងរបស់ម្ចាស់អលនទ្រព្យ។ អ្នករចនាប្លង់សួន និង LBUD នឹងជួយតម្រង់ទិសដល់ម្ចាស់អចលនទ្រព្យ អំពីលិខិតអនុញ្ញាតបើចាំបាច់។ សម្រាប់ព័ត៌មានអំពីលិខិតអនុញ្ញាតរឿងដើមឈើរបស់សាលាក្រុងឡុងប៊ិច សូមទូរស័ព្ទ  (562) 570-2770។
- ព័ត៌មានជាក់លាក់មួយចំនួន ពាក់ព័ន្ធនឹងប្រាក់ជំនួយ និងប្រាក់លើកទឹកចិត្ត ដែល LBUD ផ្តល់ជូនអតិថិជន និងអ្នកម៉ៅការ គឺអាចត្រូវជាប់លក្ខខណ្ឌក្នុងច្បាប់ស្តីពីកំណត់ហេតុសាធារណៈនៃរដ្ឋកាលីហ្វ័រញ៉ា។ ព័ត៌មានដូចជាឈ្មោះ និងអាសយដ្ឋានរបស់អ្នកពាក្យសុំ និងចំនួនទឹកប្រាក់ដែលជាជំនួយ ឬប្រាក់លើកទឹកចិត្ត ដែលត្រូវទទួលនោះ នឹងក្លាយជាព័ត៌មានសាធារណៈ បើក្នុងករណីដែលច្បាប់ស្តីពីកំណត់ហេតុសាធារណៈតម្រូវឲ្យធ្វើបែបនេះ។

## កិច្ចព្រមព្រៀងរបស់អតិថិជន

- ម្ចាស់អចលនទ្រព្យព្រមព្រៀងឲ្យសាលាក្រុងរួចផុតពីការទទួលខុសត្រូវទាំងអស់ ពាក់ព័ន្ធនឹងកម្មវិធីធ្វើសួន តំបន់ដែលត្រូវរៀបចំសួនឡើងវិញ ឬសេវាម៉ៅការ ឬផលិតផលទាំងឡាយ ដែលត្រូវធ្វើជាផ្នែកនៃកម្មវិធីនេះ។ ការទាមទារណាមួយពីម្ចាស់អចលនទ្រព្យ អាចផ្អែកលើការខូចខាត ឬខកខានក្នុងការបំពេញសេវាទៅតាមការសន្យា ឧបករណ៍ ឬសម្ភារៈដែលផ្តល់ជូនដោយកម្មវិធីនេះ ត្រូវដាក់ប្តឹងទៅអ្នកម៉ៅការ ឬរោងចក្រផលិត/អ្នកចែកចាយ។
- ម្ចាស់អចលនទ្រព្យព្រមព្រៀង ផ្តល់ជូនសាលាក្រុង និងនាយកដ្ឋានផ្សេងរបស់ក្រុង (និងលើសពី LBUD) ក្រុមប្រឹក្សា គណៈកម្មការ នាយក មន្ត្រី និយោជិត ភ្នាក់ងារ និងអ្នករចនាប្លង់ (ជារួមគឺ“ក្រុង”) នូវការអនុញ្ញាតដែលមិនអាចលុបចោលវិញមួយបាន ដើម្បីថតរូប និងភិនភាគ និង/ឬរូបភាពនៃតំបន់ដែលត្រូវរៀបចំសួនឡើងវិញរបស់អ្នកដាក់ពាក្យសុំ និងរូបអចលនទ្រព្យជាក់ស្តែង និងផ្ទាល់ខ្លួនរបស់អ្នកដាក់ពាក្យសុំ ដោយមានទាំងរូបវីដេអូ រូបថតមានចលនា ខ្សែអាត់សំឡេង និងរូបភាពផ្សេងទៀត

(ហៅជារួមថា "រូបភាព")។ ម្ចាស់អចលនទ្រព្យទទួលស្គាល់ថា រូបភាពទាំងនោះជារបស់សាលាក្រុងឡុងប៊ិច និងម្ចាស់អចលនទ្រព្យផ្តល់សិទ្ធិអនុញ្ញាផ្នែកកម្មសិទ្ធិបញ្ញា ដល់សាលាក្រុង ក្នុងការដាក់បង្ហាញ ផ្សព្វផ្សាយ ចែកចាយ ប្រើប្រាស់ កែរូប បោះពុម្ព និង បោះពុម្ពឡើងវិញ ក្នុងទម្រង់ណាមួយទៅតាមសេចក្តីត្រូវការរបស់សាលាក្រុង រួមទាំងការពុំមានភាពកំហិតក្នុងបោះពុម្ព ការផ្សាយពាណិជ្ជកម្ម ខិត្តប័ណ្ណផ្សព្វផ្សាយ រូបភាពសម្រាប់គេហទំព័រ ឬ ការបង្ហាញតាមប្រព័ន្ធអេឡិចត្រូនិកផ្សេងទៀត និងការ បញ្ជូនរូបភាពទាំងនេះផង។

- ម្ចាស់អចលនទ្រព្យលះបង់សិទ្ធិរបស់ខ្លួនទាំងអស់ ក្នុងការពិនិត្យ ឬឯកភាពជាមុនលើរូបទាំងនោះ មុន សាលាក្រុងប្រើប្រាស់វា។ ម្ចាស់អចលនទ្រព្យសូមលះបង់ការទាមទារឲ្យសាលាក្រុងទទួលខុសត្រូវ ណាមួយ ដែលកើតចេញពីការប្រើប្រាស់រូបភាពទាំងនោះ ទៅក្នុងទម្រង់ណាមួយ ឬតាមប្រព័ន្ធផ្សព្វផ្សាយ ណាមួយ និងប្រកាសឲ្យសាលាក្រុងរួចពីសំណង និងការប្តឹងផ្តល់ផ្សេងៗ ពាក់ព័ន្ធនឹងការប្រើប្រាស់ រូបភាពទាំងនោះ ដោយរួមទាំងការមិនដាក់កំហិត ការប្តឹងទាមទារអំពីការបំពានសិទ្ធិឯកជនភាព ឬសិទ្ធិផ្សព្វផ្សាយជាសាធារណៈ។
- ម្ចាស់អចលនទ្រព្យយល់ព្រមដាក់ឲ្យ LBUD និង/ឬភ្នាក់ងាររបស់ខ្លួន ប្រើប្រាស់តំបន់ដែលត្រូវរៀបចំធ្វើ សួនថ្មី និងអលនទ្រព្យនោះ បានទៅតាមសេចក្តីត្រូវការ ដើម្បីឲ្យភាគីទាំងពីរអាចប្រើប្រាស់វា ទាំងក្នុងអំឡុងពេលថតរូប និងក្រោយពេលថតរូប និងវីដេអូនៃតំបន់ដែលត្រូវធ្វើសួនឡើងវិញ សម្រាប់ គោលបំណងនៃការផ្សព្វផ្សាយ ដែលការផ្សព្វផ្សាយទាំងនោះអាចមានក្នុងទម្រង់ជាការការបោះពុម្ពផ្សាយ ការផ្សាយតាមអ៊ិនធើណិត ឬមធ្យោបាយផ្សេងទៀត ហើយម្ចាស់អចលនទ្រព្យព្រមព្រៀងដែរ ថាខ្លួន គ្មានផលប្រយោជន៍កម្មសិទ្ធិណាមួយ នៅក្នុងការរចនានៃតំបន់ដែលត្រូវរៀបចំធ្វើសួនឡើងវិញនោះ ឬប្លង់ ឬឯកសារដទៃទៀត ដែលបញ្ជាក់អំពីការរចនានេះនោះឡើយ។

**ពាក្យសុំរបស់អតិថិជន**

ពាក្យសុំណាមួយដែលមានព័ត៌មានមិនត្រឹមត្រូវ ឬព័ត៌មានធ្វើឲ្យមានការភាន់ច្រឡំ នឹងមិនអនុញ្ញាតឲ្យចូលរួម ក្នុងកម្មវិធីធ្វើសួននេះនោះឡើយ។ ក្នុងករណីនេះ រាល់ការសន្យារបស់ LBUD ពាក់ព័ន្ធនឹងពាក្យសុំនោះ រួមទាំងការសន្យាចំពោះការធ្វើសួនឡើងវិញនេះ គឺត្រូវដកមកវិញដោយស្វ័យប្រវត្តិ និងត្រូវចាត់ទុកជាមោឃៈ។

- ម្ចាស់អចលនទ្រព្យអាចដាក់ពាក្យសុំកម្មវិធីធ្វើសួននេះ បានតែមួយប៉ុណ្ណោះ ក្នុងគណនីប្រើប្រាស់ទឹកមួយ។ បើនរណាម្នាក់/ក្រុមហ៊ុនណាមួយ មានអចលនទ្រព្យច្រើន មានតែពាក្យសុំធ្វើសួននេះតែមួយប៉ុណ្ណោះ ដែលនឹងត្រូវបានសិទ្ធិទទួលបានជំនួយពីកម្មវិធីនេះ។
- ម្ចាស់អចលនទ្រព្យទទួលស្គាល់ថា ថវិកាជំនួយសម្រាប់កម្មវិធីនេះ គឺមានកំណត់។ កម្មវិធីនេះ ផ្តល់ជូនទៅតាមអ្នកដាក់ពាក្យមុនបានមុន រហូតអស់ជំនួយ ឬកម្មវិធីត្រូវលុបចោល។

- ម្ចាស់អចលនទ្រព្យ បើដាក់ពាក្យសុំជំនួយធ្វើសូនឡើងវិញនេះតាមប្រព័ន្ធអនឡាញ អាចតម្រូវឲ្យចុះហត្ថលេខាលើពាក្យសុំជាក្រដាស ក្នុងរយៈពេលពីរ (០២) សប្តាហ៍ក្រោយបានទទួលការជូនដំណឹងថាពាក្យសុំនោះត្រូវបានយល់ព្រម ដោយខាង LBUD ជាអ្នករៀបចំលិខិតស្នាមនោះជូនទៅម្ចាស់អចលនទ្រព្យ ដើម្បីចុះហត្ថលេខា។

**ការទទួលខុសត្រូវរបស់ LBUD**

ស្ថាប័ននេះត្រូវមានសិទ្ធិអំណាចទាំងស្រុង ក្នុងការដោះស្រាយវិវាទទាំងអស់ ពាក់ព័ន្ធនឹងការកម្មវិធីជំនួយដើម្បីធ្វើសូនឡើងវិញនេះ រួមទាំងការយល់ព្រមលើពាក្យសុំ និងបញ្ហាពាក់ព័ន្ធដទៃទៀត ពាក់ព័ន្ធនឹងកម្មវិធីនេះ។

**លក្ខខណ្ឌប្រាក់ចំណូលរបស់អតិថិជន**

អតិថិជនត្រូវផ្តល់ភស្តុតាងអំពីប្រាក់ចំណូល ដើម្បីឲ្យត្រូវលក្ខខណ្ឌ ដោយត្រូវបង្ហាញស្ថានភាពណាមួយ ឬច្រើនដូចខាងក្រោមនេះ។ (សូមមើលតារាងអំពីលក្ខខណ្ឌនៃប្រាក់ចំណូលនៅខាងក្រោម)៖

- តំបន់គម្រោងដែលចូលក្នុងតំបន់ផែនទី ដែលកំណត់ដោយទីភ្នាក់ងារការពារបរិស្ថានរដ្ឋកាលីហ្វ័រញ៉ា, ផែនទីសហគមន៍ដែលមើលរម្លង SB 535៖
  https://experience.arcgis.com/experience/1c21c53da8de48f1b946f3402fbae55c/page/SB-535-Disadvantaged-Communities/
- ជំនួយសាធារណៈមានដូចជា៖ SSI, SSP, SSDI ឬ CalWORKs។ (លិខិតមួយចេញពីទីភ្នាក់ងារ ឬរបាយការណ៍ធនាគារ ដែលបញ្ជាក់ថាបានជំនួយជាសាធារណៈ ដែលចេញជូនបងប្អូន កាលពីឆ្នាំមុន)
- លក្ខខណ្ឌប្រាក់ចំណូលក្រោមកម្មវិធី LIHEAP ឬ LIHWAP៖ (លិខិតមួយចេញពីទីភ្នាក់ងារដែលបានចេញប័ណ្ណនោះ ដើម្បីបញ្ជាក់ថាបងប្អូនពិតជាបានទទួលជំនួយរដ្ឋកាលពីឆ្នាំមុន)៖
  csd.ca.gov/Pages/LIHEAP-Income-Eligibility.aspx
- ក្រដាសបង់ពន្ធជាតិទម្រង់ 1040 ឬបង់ពន្ធរដ្ឋទម្រង់ 540 ដែលបានបង់ចុងក្រោយបំផុត **និង** ឯកសារចម្លងនៃបង្កាន់ដៃប្រាក់ឈ្នួលពីកន្លែងធ្វើការ សម្រាប់រយៈពេល ៣០ ថ្ងៃចុងក្រោយ ដោយបង្ហាញប្រាក់ឈ្នួលសរុបដែលទទួលបានក្នុងមួយឆ្នាំ គិតមកដល់ពេលនេះ។ (ត្រូវផ្ទៀងផ្ទាត់ទៅតាមលក្ខខណ្ឌកំណត់សម្រាប់ឆ្នាំសារពើពន្ធ ២០២៣ របស់នាយកដ្ឋានលំនៅឋាន និងអភិវឌ្ឍន៍ទីក្រុង សម្រាប់អចលនទ្រព្យរបស់បងប្អូន)៖
  https://www.huduser.gov/portal/datasets/il/il2023/2023summary.odn?STATES=6.0&INPUTNAME=METRO31080MM4480*0603799999%2BLos+Angeles+County&statelist=&stname=California&wherefrom=%24wherefrom%24&statefp=06&year=2023&ne_flag=&selection_type=county&incpath=%24incpath%24&data=2023&SubmitButton=View+County+Calculations

**ការដាក់ពាក្យ**

កាលណាយើងទទួលបានពាក្យសុំរបស់បងប្អូនរួច នាយកដ្ឋានទឹកភ្លើងរបស់ក្រុងឡុងប៊ិច នឹងបញ្ជាក់ភ័ស្តុតាងនៃប្រាក់ចំណូល ដោយផ្អែកលើលក្ខខណ្ឌប្រាក់ចំណូលដូចខាងក្រោម។ ភ័ស្តុតាងត្រូវតែដាក់អមជាមួយទម្រង់នៃកិច្ចព្រមព្រៀងកម្មវិធីធ្វើសួននេះ ដែលមានចុះហត្ថលេខារួច និងត្រូវផ្ញើទៅកាន់៖

<u>អ៊ីម៉ែលឯកសារជា PDF ទៅ</u>៖

waterconservation@lbwater.org

<u>ផ្ញើតាមប៉ុស្តិ៍សំបុត្រទៅ៖</u>

Water Conservation
Long Beach Water Department
1800 E Wardlow Rd. Long Beach, CA 90807



LONGBEACH Utilities
Water · Gas · Sewer

## 2023 LIHWAP & LIHEAP Household Income Eligibility*

| Persons In Household | Monthly Income |
|---|---|
| 1 | $2,700.17 |
| 2 | $3,531.00 |
| 3 | $4,361.83 |
| 4 | $5,192.75 |
| 5 | $6,023.59 |
| 6 | $6,854.43 |
| 7 | $7,010.21 |
| 8 | $7,166.00 |
| 9 | $7,321.78 |
| 10* | $7,477.56 |

*Households with a CalFresh, CalWORKs, or the Low Income Home Energy Assistance Program (LIHEAP) recipient are already income-qualified for LIHWAP.
**For families/households with more than 10 persons, add $155.78 for each additional person.

## FY 2023 Income Limits Summary

| FY 2023 Income Limit Area | Median Family Income Click for More Detail | FY 2023 Income Limit Category | Persons in Family | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | | | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 |
| **Los Angeles-Long Beach-Glendale, CA HUD Metro FMR Area** | $98,200 | Very Low (50%) Income Limits ($) Click for More Detail | 44,150 | 50,450 | 56,750 | **63,050** | 68,100 | 73,150 | 78,200 | 83,250 |
| | | Extremely Low Income Limits ($)* Click for More Detail | 26,500 | 30,300 | 34,100 | **37,850** | 40,900 | 43,950 | 46,950 | 50,560 |
| | | Low (80%) Income Limits ($) Click for More Detail | 70,650 | 80,750 | 90,850 | **100,900** | 109,000 | 117,050 | 125,150 | 133,200 |